## សរុបព្រឹត្តការណ៍ប្រចាំថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

## សម្រាប់ វីរុស COVID-19

### ១. ដើមអម្ពិល៖ ជំងឺ COVID-19៖ ហុងកុង នឹងផ្តល់ប្រាក់ ១ម៉ឺនដុល្លារហុងកុង ដល់ពលរដ្ឋរស់នៅអចិន្ត្រៃយ៍ អាយុលើសពី ១៨ឆ្នាំ ដើម្បីបន្ថយផលប៉ះពាល់

គេហទំព័រដើមអម្ពិល

ដើមអម្ពិល DAP NEWS

ព័ត៌មានអន្តរជាតិ

**ជំងឺ COVID-19៖ ហុងកុង នឹងផ្តល់ប្រាក់ ១ម៉ឺនដុល្លារហុងកុង ដល់ពលរដ្ឋរស់នៅអចិន្ត្រៃយ៍ អាយុលើសពី ១៨ឆ្នាំ ដើម្បីបន្ថយផលប៉ះពាល់**

By KD102

Posted on February 28, 2020

បរទេស៖ កាលពីថ្ងៃពុធរដ្ឋាភិបាលហុងកុង បានប្រកាសថា ខ្លួននឹងផ្តល់ឱ្យអ្នករស់នៅជា អចិន្ត្រៃយ៍របស់ខ្លួននូវប្រាក់ចំនួន ១.២៨០ ដុល្លារក្នុងម្នាក់ៗ ដើម្បីជាវិធានការណ៍ជួយសង្គ្រោះ ហិរញ្ញវត្ថុចំពេលដែលការផ្ទុះឡើង នៃជំងឺរលាកផ្លូវដង្ហើម COVID-19។ នេះបើតាមការចេញផ្សាយ របស់សារព័ត៌មាន Sputnik កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។

Adtag for Mobile Underlay:-
នៅក្នុងការចេញផ្សាយរបស់សារព័ត៌មាន Asia Times គឺនៅក្នុងសុន្ទរកថាមួយដែលប្រកាស អំពីវិធានការណ៍ថ្មីនេះលោក Paul Chan លេខាធិការក្រសួងហិរញ្ញវត្ថុ ទីក្រុងបានទទួលស្គាល់ថា“ មានបរិយាកាសអាប់អួរ” ។

លោក Chan បានមានប្រសាសន៍ថា“ បន្ទាប់ពីបានពិចារណាយ៉ាងហ្មត់ចត់ ខ្ញុំបានសំរេចចិត្តចំណាយ ១០.000 ដុល្លារហុងកុង ទៅអោយអ្នករស់នៅអចិន្ត្រៃយ៍ នៅហុងកុងដែលមានអាយុ ១៨ ឆ្នាំឡើងទៅដោយមានគោលបំណង លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ក្នុងស្រុកមួយ និងជួយសម្រាលបន្ទុក ហិរញ្ញវត្ថុរបស់ប្រជាជន។ នេះបើតាមការចុះផ្សាយ របស់សារព័ត៌មាន Asia Times ។

ទោះយ៉ាងណាការប្រគល់ប្រាក់ជា សាច់ប្រាក់នឹងត្រូវផ្តល់ជូនតែចំពោះ អ្នករស់នៅជាអចិន្ត្រៃយ៍ នៅហុងកុងប៉ុណ្ណោះ។ អនីតិជនកម្មករចំណាកស្រុក និងជនអន្តោប្រវេសន៍ថ្មី មិនត្រូវបានរាប់បញ្ចូលពីការ ប្រគល់នេះទេ-ជាការសម្រេចចិត្តមួយដែល ត្រូវបានរិះគន់ដោយលោក Ben Chan Han Pan សមាជិកសភានៃសម្ព័ន្ធភាពប្រជាធិបតេយ្យដើម្បី ភាពល្អប្រសើររបស់ហុងកុង និងលោក Wu Chi Wai សមាជិកសភាគណបក្ស ប្រជាធិបតេយ្យ ៕

ប្រែសម្រួល៖ ណៃ តុលា

## ២. កម្ពុជាថ្មី៖ វៀតណាមឈប់ឱ្យអ្នកធ្វើដំណើរមកពីតំបន់រងគ្រោះវីរុស COVID-19 នៅកូរ៉េខាងត្បូង ចូលប្រទេសខ្លួនបណ្ដោះអាសន្ន

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY

ប្រាសាក់ នៅតែបន្តដំឡើង អត្រាការប្រាក់បញ្ញើសន្សំ 8%
023 / 086 999 911
www.prasac.com.kh

Amret mobile ចុចទីនេះដើម្បីទាញយក App Store Google play



# វៀតណាមឈប់ឱ្យអ្នកធ្វើដំណើរមកពីតំបន់រងគ្រោះវីរុស covid-19 នៅកូរ៉េខាងត្បូង ចូលប្រទេសខ្លួនបណ្ដោះអាសន្ន

28/2/2020 9:07 Am KPT Plus, សុខភាព

like

នៅក្នុងបទបញ្ជាថ្មីនេះនាយករដ្ឋមន្ត្រី Nguyen Xuan Phuc បានស្នើទៅក្រសួងការបរទេសឱ្យជូនដំណឹងជាបន្ទាន់ដល់កូរ៉េខាងត្បូងនិងប្រទេសនិងប្រទេសដទៃទៀតអំពីវិធានការដែលត្រូវបានអនុម័តថ្មីៗរបស់ប្រទេសវៀតណាមដើម្បីការពារការរីករាលដាលនៃការឆ្លងវីរុស COVID-19។

យោងតាមការចុះផ្សាយរបស់កាសែត South China Morning Post បាន ឲ្យដឹង ថា COVID-19 បានលេចមុខជាលើកដំបូងនៅក្នុងទីក្រុងអ៊ូហានរបស់ប្រទេសចិន កាលពីខែធ្នូ ឆ្នាំ ២០១៩ បានឆ្លងដល់មនុស្សជាង ៨២000 នាក់និងបានសម្លាប់មនុស្សចំនួន ២៨00 នាក់នៅទូទាំងពិភពលោកគិតត្រឹមថ្ងៃពុធ។

---

បើយោងតាមសារព័ត៌មាន Reuters បាននិយាយថា ប្រទេសកូរ៉េខាងត្បូងបានបញ្ជាក់ថាមានអ្នកស្លាប់ចំនួន ១២ នាក់និងឆ្លងជំងឺជិត ១៦00 នាក់មកទល់ពេលនេះ ដោយភាគច្រើននៃពួកគេនៅ Daegu ដែលជាទីក្រុងធំជាងគេទី ៤ របស់ខ្លួននិងនៅខេត្ត Gyeongsang ខាងជើង ដែលជាខេត្តនៅជិតខាងជាមួយទីក្រុង Daegu ។ ទីភ្នាក់ងារព័ត៌មាន Reuters បានរាយការណ៍បន្ថែមថា កូរ៉េខាងត្បូងមានចំនួនភ្ញៀវទេសចរចំនួន ១៨ លាននាក់របស់ប្រទេសវៀតណាមកាលពីឆ្នាំមុន ដែលជាក្រុមភ្ញៀវទេសចរច្រើនបំផុតបន្ទាប់ពីភ្ញៀវទេសចរចិន ដែលការធ្វើដំណើររបស់ពួកគេត្រូវបានកាត់បន្ថយដោយសារតែមេរោគ។ យោងតាមវិធានការណ៍របស់ប្រទេសវៀតណាមក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃ COVID-19 អ្នកធ្វើដំណើរទាំងអស់ មកពីតំបន់ណាមួយដែលបានរាយការណ៍ពីករណីនៃវីរុស COVID-19 រួមទាំងផ្នែកខ្លះនៃប្រទេសកូរ៉េត្រូវបានផ្អាកពីការចូលប្រទេសវៀតណាមដូចគ្នា។ អ្នកដែលធ្វើដំណើរមកប្រទេសវៀតណាមសម្រាប់ភារកិច្ចផ្លូវការពិសេសនឹងត្រូវធ្វើសេចក្តីប្រកាសអំពីសុខភាពរួចត្រូវដាក់ដោយឡែករយៈពេល ១៤ ថ្ងៃ បន្ទាប់ពីការមកដល់ស្របតាមបទបទបញ្ញត្តិបច្ចុប្បន្ន។

ជនជាតិវៀតណាមដែលកំពុងរស់នៅនិងធ្វើការនៅប្រទេសកូរ៉េខាងត្បូងជាពិសេសនៅទីក្រុង Daegu និងខេត្ត Gyeongsang ខាងជើងគួរតែអនុវត្តតាមការណែនាំយ៉ាងម៉ឺងម៉ាត់ស្តីពីការការពារនិងការរាតត្បាតនៃប្រទេសម្ចាស់ផ្ទះ។ ពលរដ្ឋវៀតណាមដែលវិលត្រឡប់មកពីតំបន់ដែលរងផលប៉ះពាល់ដោយ COVID-19 នៅក្នុងប្រទេសកូរ៉េខាងត្បូងក៏នឹងត្រូវដាក់ឱ្យនៅដាច់ពីគ្នារយៈពេល ១៤ ថ្ងៃផងដែរ។

ក្រសួងសន្តិសុខសាធារណៈនឹងផ្តល់ព័ត៌មានអំពីអ្នកធ្វើដំណើរចូលមកជាមួយកំណត់ត្រាធ្វើដំណើរទៅកាន់តំបន់រងគ្រោះដល់ក្រសួងការពារជាតិ ក្រសួងសុខាភិបាលនិងគណៈកម្មាធិការប្រជាជននៃខេត្តនិងក្រុងដែលពាក់ព័ន្ធដើម្បីអនុវត្តវិធានការណ៍ដាក់ដោយឡែក។ ក្រសួងសន្តិសុខសាធារណៈមានភារកិច្ចផ្តល់ព័ត៌មានអំពីអ្នកដំណើរមកពីកូរ៉េខាងត្បូង ដែលបានចូលប្រទេសវៀតណាមចាប់ពីថ្ងៃទី ១១ ខែកុម្ភៈឆ្នាំ ២០២០ ដើម្បី ឲ្យ អាជ្ញាធរមូលដ្ឋានត្រួតពិនិត្យសុខភាពរបស់ពួកគេ និងផ្តាច់ពួកគេឱ្យបានទាន់ពេលវេលាបើចាំបាច់។

រហូតមកដល់ពេលនេះប្រទេសវៀតណាមបានរាយការណ៍ថាមានករណីឆ្លងវីរុសចំនួន ១៦ ករណីក្នុងនោះមានជនជាតិវៀតណាម ១៣ នាក់អាមេរិកម្នាក់និងចិន ២ នាក់។ ពួកគេទាំងអស់បានជាសះស្បើយយ៉ាងពេញលេញ និងត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យនៅព្រឹកថ្ងៃពុធកន្លងទៅនេះ។

ប្រទេសនេះមិនមានការឆ្លងថ្មីទេចាប់តាំងពីថ្ងៃទី ១៣ ខែកុម្ភៈ ៕

ប្រែសម្រួលៈសាង ស្រីល័ក្ខ

## ៣. កម្ពុជាថ្មី៖ ប្រទេសអ៊ីរ៉ង់ទទួលបានឧបករណ៍ធ្វើតេស្តមេរោគកូរ៉ូណាចំនួន ២ ម៉ឺនគ្រឿងពីប្រទេសចិន

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY












# ប្រទេសអ៊ីរ៉ង់ទទួលបានឧបករណ៍ធ្វើតេស្តមេរោគកូរ៉ូណាចំនួន ២ ម៉ឺនគ្រឿងពីប្រទេសចិន

28/2/2020 8:59 Am KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព

like

អ្នកនាំពាក្យក្រសួងការបរទេសនៃសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់បានប្រកាសថា ខ្លួននឹងទទួលបានឧបករណ៍ធ្វើរោគវិនិច្ឆ័យរកវីរុស Covid-19 ចំនួន ២០ ០០០ គ្រឿងពីប្រទេសចិន។

នៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃព្រហស្បតិ៍លោក Seyyed Abbas Mousavi អ្នកនាំពាក្យក្រសួងការបរទេសបានគូសបញ្ជាក់ពីវិធានការណ៍នានាដែលអនុវត្តដោយក្រសួងការបរទេសអ៊ីរ៉ង់ ដើម្បីជួយដល់វិស័យសុខាភិបាលនិងវេជ្ជសាស្ត្រដែលកំពុងធ្វើការយ៉ាងស្វិតស្វាញក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងវីរុស Covid-19 ។

លោក Mousavi បាននិយាយថា ផែនការទទួលបានជំនួយស្ម័គ្រចិត្តពីបណ្តាប្រទេសជាមិត្តត្រូវបានអនុវត្តនិងកំពុងតែដំណើរការជាបណ្តើរៗហើយ។

ការឧបត្ថម្ភជាដំបូងលើបញ្ហានេះ ត្រូវបានផ្តល់ដោយរដ្ឋាភិបាលចិននិងកាកបាទក្រហមដែលរួមមានឧបករណ៍ធ្វើតេស្តរកវីរុសប្រហែល ២០០០០ គ្រឿងនិងឧបករណ៍ផ្គត់ផ្គង់មួយចំនួនទៀត ហើយវានឹងត្រូវបញ្ជូនទៅកាន់ប្រទេសអ៊ីរ៉ង់នៅថ្ងៃសុក្រនេះដោយមានជើងហោះហើរពិសេស។

លោក Mousavi បានសរសើររដល់ដ្ឋាភិបាលនិងប្រជាជនចិនចំពោះជំនួយដ៏សប្បុរសរបស់ពួកគេដោយបន្ថែមថា ព័ត៌មានលម្អិតបន្ថែមទៀតអំពីជំនួយដែលផ្តល់ដោយប្រទេសចិននិងបណ្តាប្រទេសជាមិត្តផ្សេងទៀតនឹងត្រូវប្រកាសបន្ទាប់ពីអ៊ីរ៉ង់បានទទួលជំនួយទាំងនោះ៕

ចុចអាន៖  ជម្លោះរវាងសាសនានិងវិទ្យាសាស្ត្រពីវីរុស Covid-19 កំពុងតែរាលដាលក្នុងប្រទេសអ៊ីរ៉ង់

ចុចអាន៖ អ៊ីរ៉ង់និយាយថា ខ្លួនត្រៀមជាស្រេចដើម្បីផលិតឧបករណ៍អនាម័យសម្រាប់ការពារវីរុស Covid-19

ប្រែសម្រួល៖ សន្យា

**៤. កម្ពុជាថ្មី៖ព្រឹកនេះអ្នកឆ្លងកូរ៉ូណានៅកូរ៉េខាងត្បូងឡើងដល់ជាង ២០០០នាក់ ក្រោយរកឃើញករណីថ្មី ២៥៦នាក់ទៀត**

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY











# ព្រឹកនេះអ្នកឆ្លងកូរ៉ូណានៅកូរ៉េខាងត្បូងឡើងដល់ជាង ២០០០នាក់ ក្រោយរកឃើញករណីថ្មី ២៥៦នាក់ទៀត

28/2/2020 8:50 Am  KPT Plus, ព័ត៌មានអន្តរជាតិ  1

ប្រទេសកូរ៉េខាងត្បូងនៅព្រឹកថ្ងៃសុក្រ ទី២៨ ខែកុម្ភៈនេះបាន រាយការណ៍នូវករណីឆ្លងវីរុស COVID-19 ថ្មីចំនួន ២៥៦ ករណី នាំឱ្យចំនួនអ្នកឆ្លងសរុបមកដល់ទីនេះចំនួន ២០២២នាក់ ដែលជាកំណើនលើសជាងប្រទេសចិនទៅទៀតនៅពេលនេះ។
រហូតមកដល់ពេលនេះមានមនុស្សចំនួន ១៣ នាក់បានស្លាប់នៅក្នុងប្រទេសកូរ៉េខាងត្បូងដោយសារវីរុសដែលលេចចេញពីប្រទេសចិននេះ។

ច្រើនជាងពាក់កណ្តាលនៃករណីដែលបានបញ្ជាក់ថ្មីៗសុទ្ធតែជាអ្នកមានទំនាក់ទំនងនឹងក្រុមនិកាយសាសនាគ្រិស្តងព្រះវិហារមួយនៅភាគអាគ្នេយ៍នៃទីក្រុង Daegu ។

ក្នុងចំណោមករណីថ្មីទាំង ២៥៦ ករណីមានចំនួន ១៨២ ករណីស្ថិតនៅក្នុងទីក្រុង Daegu និង ៤៩ ករណីស្ថិតនៅក្នុងខេត្ត North Gyeongsang ដែលនៅក្បែរនោះ។ ចំនួនសរុបនៃការឆ្លងនៅទីក្រុង Daegu មានចំនួន ១៣១៤ និងនៅខេត្ត North Gyeongsang មានចំនួន ៣៩៤ ។

មជ្ឈមណ្ឌលគ្រប់គ្រងនិងការពារជំងឺកូរ៉េ (KCDC) បាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថានៅតាមបណ្តាខេត្តនិងទីក្រុងសំខាន់ៗផ្សេងទៀតក៏បានរាយការណ៍ពីការឆ្លងមួយចំនួនផងដែរដោយទីក្រុងសេអ៊ូលបានរាយការណ៍ពីករណីថ្មីចំនួន ៦។
ទីក្រុង Daejeon បានរាយការណ៍ករណីថ្មីចំនួន ៤ និងទីក្រុង Busan មានករណីថ្មីចំនួន ២។

ចាប់តាំងពីការបង្កើនកម្រិតប្រកាសអាសន្នវីរុសនេះដល់កម្រិត "ក្រហម" ដែលជាកម្រិតខ្ពស់បំផុតកាលពីថ្ងៃអាទិត្យ អាជ្ញាធរសុខាភិបាលបានផ្តោតលើការបញ្ឈប់ការរីករាលដាលនៅទីក្រុង Daegu ដែលជាតំបន់មានការផ្ទុះខ្លាំងបំផុត និងនៅខេត្ត North

Gyeongsang ។

ក្រុមអ្នកជំនាញបាននិយាយថាចំនួនករណីឆ្លងត្រូវបានគេរំពឹងថាលោតឡើងខ្លាំងនៅសប្តាហ៍នេះ ខណៈដែលអាជ្ញាធរសុខាភិបាលបានចាប់ផ្តើមធ្វើតេស្តិ៍សមាជិកសាសនាគ្រិស្តជាង ២សែននាក់នៃព្រះវិហារ Shincheonji នៅទីក្រុង Daegu ៕

ប្រែសម្រួល៖ វ៉ាន់ថន

### ៥.រស្មីកម្ពុជា៖ មន្ត្រីជំនាញថា លាងដៃនិងបន្ថយប៉ះផ្ទៃមុខ មានប្រសិទ្ធភាពបំផុតក្នុងការបង្ការជំងឺកូរ៉ូណា


រស្មីកម្ពុជា

ដំណឹងក្នុងប្រទេស ក្នុងប្រទេស សុខាភិបាល - អប់រំ

# មន្ត្រីជំនាញថា លាងដៃនិងបន្ថយប៉ះផ្ទៃមុខ មានប្រសិទ្ធភាពបំផុតក្នុងការបង្ការជំងឺកូរ៉ូណា

February 28, 2020, 6:31 AM 59

ដោយៈមេសា/ភ្នំពេញៈ នៅក្នុងបាឋកថាពន្យល់ដល់អ្នកសារព័ត៌មាន នៅឯវិទ្យាស្ថានជាតិសុខភាពសាធារណៈ លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ អ្នកនាំពាក្យក្រសួងសុខាភិបាល បានលើកឡើងថា វិធីដ៏សាមញ្ញ និងមានប្រសិទ្ធភាពបំផុតក្នុងការការពារពីការឆ្លងជំងឺកូវីដ១៩ ឬ COVID-19 ដោយរួមទាំងជំងឺឆ្លងជាច្រើនប្រភេទផ្សេងទៀតផងនោះ គឺ ការលាងដៃឱ្យបានជ្រះស្អាត លាងឱ្យបានញឹកញាប់ និងកាត់បន្ថយការយកដៃប៉ះបរិវេណផ្ទៃមុខឱ្យនៅតិចបំផុត ។



លោកវេជ្ជបណ្ឌិត លី ស៊ូវ៉ាន់ ពន្យល់ថា ការឆ្លងជំងឺពីមនុស្ស ម្នាក់ ទៅអ្នកផ្សេងទៀត មាន ២ ប្រភេទសំខាន់ គឺ ៖

១. ឆ្លងតាមខ្យល់ គឺនៅពេលអ្នកជំងឺក្អក ឬ កណ្តាស់ ជាដើម មេរោគដ៏ច្រើន ក៏រសាត់អណ្តែតនៅក្នុងលំហខ្យល់ ពេលអ្នកណាផ្សេងដកដង្ហើមស្រូបខ្យល់នោះចូលក្នុងខ្លួន មេរោគក៏ចូលទៅក្នុងខ្លួនមនុស្សទាំងនោះដែរ ។ មេរោគ ប្រភេទនេះ មានដូចជា ជំងឺរបេង , ស្អូច , កញ្ជ្រិល , អុតស្វាយជាដើម ។

២. ឆ្លងតាមតំណក់ទឹកតូចៗ នៃរាងកាយរបស់អ្នកជំងឺ ដូចជាទឹកមាត់ ទឹកនោម ឈាម ទឹករំអិល ស្លេស្ម និង សម្បោរ ជាដើម គឺមេរោគរស់នៅក្នុងវត្ថុទាំងនោះ ហើយ មេរោគអាចឆ្លងពីមនុស្សម្នាក់ទៅអ្នកដទៃ តាមរយៈ ការប៉ះ ទឹកទាំងនោះ ហើយជំងឺទាំងនោះមានដូចជា ជំងឺ ខាន់ស្លាក់ និង ផ្តាសាយ ជាដើម ហើយប្រការ

ការពាក់ម៉ាស់ មិនបានត្រឹមត្រូវ ដូចជាពាក់តែច្រមុះ ឬ តែមាត់ ឬ ពាក់ក្រោមចង្កា ឧស្សាហ៍យកដៃបេះបោចម៉ាស់ ពាក់ម៉ាស់តែមួយមិនបានបោកសម្អាត ជាដើម មិនត្រឹមតែមិនអាចការពារមេរោគប៉ុណ្ណោះទេ ថែមទាំងនាំឱ្យឆ្លងមេរោគទៀតផង ( រូប: អ៊ីនធឺណេត )

គួរកត់សម្គាល់ គឺជំងឺ កូរ៉ូណាថ្មី ឬ COVID-19 ក៏ស្ថិតនៅក្នុងប្រភេទឆ្លងបែបនេះដែរ ។
ហេតុនេះលោកវេជ្ជបណ្ឌិត លី ស៊ូវ៉ាន់ បន្ថែមថា ចូរកុំនៅប្រឈម ឬ ទល់មុខនឹងអ្នកក្អក ឬ កណ្តាស់ ចូរនៅឱ្យឆ្ងាយពីអ្នកក្អក ឬ កណ្តាស់ ឱ្យឆ្ងាយជាង ១ ម៉ែត្រ ព្រោះទឹកមាត់ជាដើម ដែលមនុស្សក្អកចេញទៅ មានចម្ងាយប្រមាណជា ១ ម៉ែត្រ ហើយត្រូវកាត់បន្ថយការយកដៃទៅប៉ះពាល់បរិវេណមុខឱ្យនៅតិចបំផុត ។

ចំពោះការប្រើប្រាស់ ម៉ាស់ វិញ លោក វេជ្ជបណ្ឌិត លី ស៊ូវ៉ាន់ បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកឈឺមិនមែនគួរតែពាក់ម៉ាស់ទេ ប៉ុន្តែគឺត្រូវតែពាក់ម៉ាស់ និង ត្រូវឧសហ្សាហ៍លាងដៃនឹងសាប៊ូ ឬ ជែល ឬ អាល់កុល ។ ចំណែកអ្នកដែលមិនមែនជាអ្នកជំងឺ មិនចាំបាច់ពាក់ម៉ាស់ទេ ប៉ុន្តែត្រូវឧស្សាហ៍លាងដៃនឹងសាប៊ូ ឬ លាងដោយជែល ព្រោះសាប៊ូអាចជម្រះសម្អាតមេរោគ ចំណែកជែល និង អាល់កុលជាដើម អាចសម្លាប់មេរោគ ។ ដូច្នេះប្រសិន

បើកគេលាងដៃដោយអាល់កុល ឬ ជែល គេត្រូវទុកដៃឱ្យស្ងួតសិន មុននឹងចាប់កាន់របស់ផ្សេង ព្រោះពេលស្ងួតដៃ បានន័យថា មេរោគបានងាប់ហើយ ។

នៅពេលសួរថា តើពេលណា ចាំបាច់ពាក់ម៉ាស់ លោកវេជ្ជបណ្ឌិត លី ស៊ូវ៉ាន់ ផ្តល់ចម្លើយថា ការពាក់ម៉ាស់ ចាំបាច់នៅពេលដែលយើងត្រូវចូលទៅក្នុងចំណោមមនុស្សច្រើន ព្រោះយើងមិនដឹងថាអ្នកណាក្អក ឬ មិនក្អកឡើយ ។ លើសពីនេះទៅ គឺពេលទៅសួរសុខទុក្ខ ឬ នៅមើលថៃអ្នកជំងឺជាដើម ប៉ុន្តែ ម៉ាស់ ដែលពាក់ហើយ ចាំបាច់ត្រូវបោះចោលកុំពាក់ម្តងទៀត ព្រោះម៉ាស់ នោះអាចភ្ជាប់ទៅដោយមេរោគរួចទៅហើយ ដូច្នេះ បើពាក់ម៉ាស់នោះម្តងទៀត មេរោគ អាចឆ្លងចូលតាមនោះដដែល ។ ប្រសិនបើត្រូវការពាក់ម៉ាស់នោះម្តងទៀត គេត្រូវតែបោក ឬ លាងជម្រះឱ្យស្អាត រួចហាលថ្ងៃឱ្យស្ងួតសិន ។

ម៉្យាងទៀត ទោះពាក់ម៉ាស់ហើយក្តី ក៏មិនត្រូវធ្វេសប្រហែសដូជាប្រឈមទល់មុខនឹងអ្នកក្អកជាដើមឡើយ ព្រោះម៉ាស់ខ្លះអាចការពារការឆ្លងមេរោគបានកម្រិតណាមួយប៉ុណ្ណោះហើយពាក់ម៉ាស់ ក៏ត្រូវតែពាក់ឱ្យជិតទាំងច្រមុះ និង មាត់ហើយកុំយកដៃទៅប៉ះម៉ាស់នោះ ព្រោះទាំងដៃ ទាំងម៉ាស់អាចជាប់ទៅដោយមេរោគច្រើនប្រភេទ ដោយសារ មនុស្សតែងតែយកដៃទៅចាប់កាន់របស់របរផ្សេងៗ ដែលគេមិនដឹងថា របរណាមានមេរោគ របស់ណាគ្មានមេរោគឡើយ ហើយអ្វីដែលគេមិនអាចទុកចិត្តទាល់តែសោះនោះ គឺរាល់របស់របរដែលគេបានចាប់កាន់នោះ ត្រូវបានចាប់កាន់ដោយមនុស្សច្រើនគ្នា ហើយដៃរបស់អ្នកទាំងនោះ គេមិនដឹងថា

ប្រទូលាក់ទៅដោយមេរោគប្រភេទណាខ្លះឡើយ ។

ក្នុងន័យនេះ លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ សង្កត់ធ្ងន់ថា មធ្យោបាយដ៏មានប្រសិទ្ធភាព និងងាយធ្វើបំផុតក្នុងការ ការពារពីការឆ្លងជំងឺមួយចំនួន ដោយរួមទាំងជំងឺ COVID-19 ផងនោះ ទី ១ គឺត្រូវលាងសម្អាតដៃ ព្រោះមនុស្ស គ្រប់គ្នា តែងតែប្រើដៃទៅចាប់កាន់របស់របរជាច្រើន ដូចជា បង្កាន់ដៃទ្វារ របស់របរប្រើប្រាស់នៅកន្លែងធ្វើការ សម្ភារ នៅក្នុងបន្ទប់ទឹក នៅក្នុងបន្ទប់បាយ ទ្វាររថយន្ត ទូរស័ព្ទ និង កុំព្យូទ័រផងជាដើម ដែលធ្វើឱ្យដៃជាប់ទៅដោយមេរោគ ដែល នៅលើរបស់របរទាំងនោះ ព្រោះរបស់របរទាំងនោះ ត្រូវបាន ប៉ះពាល់ទៅដោយដៃមនុស្សជាច្រើន ហើយប្រសិនបើមាន ដៃរបស់មនុស្សណាម្នាក់ មានមេរោគ នោះ វាប្រាកដជា ចម្លងទៅដៃ និង របស់របរជាច្រើនទៀត រួចហើយក៏យកដៃ ដែលជាប់ទៅដោយមេរោគនោះ ទៅប៉ះបរិវេណមុខ ដូចជា មាត់ ច្រមុះ ឬ ចាប់ការអាហារបរិភោគជាដើម ហើយមេរោគ ក៏ឆ្លងតាមបែបនោះឯង ព្រោះមនុស្សម្នាក់តែងតែយកដៃញី ភ្នែក ច្រមុះ ផ្ទៃមុខ ជាមធ្យម ៦០ ដង ។

រីឯការក្អក និង កណ្តាស់ ក៏គប្បីប្តូរឥរិយាបថដែរ ពោលគឺនៅពេលក្អកប្រសិនបើ មានរបស់អ្វីសម្រាប់ខ្ទប់មាត់ ដូចជាក្រមា កន្សែង ឬ ក្រដាសជាដើម ក៏ខ្ទប់មាត់ដោយរបស់ទាំងនោះចុះ ប៉ុន្តែប្រសិនបើគ្មានរបស់ទាំងនោះខ្ទប់មាត់ទេ សូមកុំយកដៃខ្ទប់មាត់ ពោលគឺកុំក្អក ឬ កណ្តាស់ ដាក់បាតដៃ ប៉ុន្តែត្រូវក្អកដាក់ដើមដៃវិញ ។ ព្រោះថា ពេលក្អក ឬ កណ្តាស់ដាក់បាតដៃ មេរោគ នឹងជាប់នឹងបាតដៃ រួចហើយពេលគេចាប់ដៃជាមួយអ្នកដទៃ ឬ ចាប់កាន់របស់របរផ្សេងៗនោះ មេរោគក៏ឆ្លងទៅអ្នកដទៃតាមនោះដែរ ។

លោកវេជ្ជបណ្ឌិត លី ស៊ូវ៉ាន់ ក៏បានបន្ថែមដែរថា ការលាងសម្អាតដៃបានល្អនោះ គេអាចកាត់បន្ថយជំងឺរាករូសបាន ៦០ ភាគរយទៀតផង ៕ Kh/Ha

## ៦. រស្មីកម្ពុជា៖ អ្នកជំនាញចិនថាCOVID-19 នឹងស្ថិតនៅក្រោមការគ្រប់គ្រងបាននៅចុងខែមេសា

រស្មីកម្ពុជា

សុខភាព-អប់រំផ្លូវភេទ | សុខភាពទូទៅ | ដំណឹងអន្តរជាតិ

# អ្នកជំនាញចិនថាCOVID-19 នឹងស្ថិតនៅក្រោមការគ្រប់គ្រងបាននៅចុងខែមេសា

February 28, 2020, 8:40 AM

66

ប្រទេសចិនបានកត់ត្រាការស្លាប់ចំនួន២៩នាក់ដោយវីរុស COVID-19កាលពីថ្ងៃពុធ ដែលជាកម្រិតទាបបំផុតក្នុងរយៈពេលមួយថ្ងៃនៅក្នុងរយៈពេលជិតមួយខែមកនេះ ស្របពេលដែលក្រុមអ្នកជំនាញផ្នែករោគរាតត្បាតជាន់ខ្ពស់ របស់ខ្លួនសង្ឃឹមថាប្រទេសនេះអាចទប់ស្កាត់វីរុសនេះបាននៅយ៉ាងយូរត្រឹមចុងខែមេសា។



ចំនួនអ្នកស្លាប់នេះគឺជាការការថយចុះគួរឱ្យកត់សម្គាល់នៅប៉ុន្មានថ្ងៃមកនេះ ដោយនៅក្រោមមួយរយនាក់ក្នុងមួយថ្ងៃ។ ឥឡូវចិនដីគោកមានមនុស្សស្លាប់សរុបដោយក្លូរ៉ូណាវីរុសថ្មីនេះចំនួន២.៧៨៨នាក់ និងអ្នកឆ្លងសរុប៧៨.៨២៤នាក់។

វេជ្ជបណ្ឌិតចិន លោកហ្សុង ណាន់សាន(Zhong Nanshan) អ្នកឯកទេសខាងជំងឺឆ្លងបាននិយាយថា អន្តរាគមន៍រហ័សរបស់ចិន ដូចជាការបិទចេញចូលក្រុងវ៉ូហាន បានជួយទប់ស្កាត់វីរុសនេះមិនឲ្យឆ្លងរាលដាលទៅទីក្រុងផ្សេងៗទៀត។

កាលពីមុននេះលោកបានព្យាករថាការឆ្លងរាលដាលនៃវីរុសនេះនឹងឈានដល់កម្រិតកំពូលនៅពាក់កណ្តាលចុងខែកុម្ភៈ ។

លោកបាននិយាយនៅក្នុងសន្និសីទកាសែតកាលពីថ្ងៃព្រហស្បតិ៍ថា ចំនួនករណីឆ្លងបានធ្លាក់ចុះចាប់តាំងពីថ្ងៃទី ១៥ ខែកុម្ភៈ។

លោកបានបន្ថែមថា “យើងជឿជាក់ថាការឆ្លងរាលដាលនៃជំងឺនេះនឹងស្ថិតក្រោមការគ្រប់គ្រងបាននៅយ៉ាងយូរត្រឹមចុងខែមេសា ” ៕ប្រែសម្រួល៖*វាសនា*/Ha

## ៧.ដើមអម្ពិល៖ ប៉ាគីស្ថាន បិទសាលារៀន និងផ្អាកជើងហោះហើរ អ៊ីរ៉ង់ ដើម្បីទប់ស្កាត់ការ ឆ្លងកូរ៉ូណាវីរុស

ដើមអម្ពិល DAP NEWS




ព័ត៌មានអន្តរជាតិ

# ប៉ាគីស្ថាន បិទសាលារៀន និងផ្អាក ជើងហោះហើរ អ៊ីរ៉ង់ ដើម្បី ទប់ស្កាត់ការ ឆ្លងកូរ៉ូណាវីរុស

By SS107

Posted on February 28, 2020

បរទេសះប្រទេសប៉ាគីស្ថាន នៅថ្ងៃព្រហស្បតិ៍នេះ បានបិទ សាលារៀន នៅក្នុងតំបន់មួយចំនួន និងបានផ្អាកជើងហោះហើរ ដែលទៅនិមកពីប្រទេសអ៊ីរ៉ង់ ដើម្បីប្រឹងប្រែងទប់ស្កាត់ការរីក រាលដាលឆ្លងនៃកូរ៉ូណាវីរុសថ្មី ក្រោយបានរាយការណ៍ ពីករណី ដំបូងនៃជម្ងឺផ្លូវដង្ហើមថ្មីនេះ។

Adtag for Mobile Underlay:-
អាជ្ញាធរបាគីស្ថាន តាមសេចក្តីរាយការណ៍ បានបិទសាលារៀន នានា នៅក្នុងខេត្ត Sindh ស្ថិតនៅភាគខាងត្បូងប្រទេស រួមបញ្ចូល ទាំងទីក្រុង Karachi ជាទីក្រុងដ៏ធំបំផុតរបស់ ប្រទេសប៉ាគីស្ថាន និងជាទីដែលគេរាយការណ៍ រកឃើញករណីកូរ៉ូណាវីរុស ហើយនិង សាលារៀន នៅក្នុងខេត្ត Baluchistan ដែលស្ថិតនៅភាគនិរតី នៃ ប្រទេសជាប់ព្រំដែន ប្រទេសអ៊ីរ៉ង់។

គួរបញ្ជាក់ថា ប្រទេសប៉ាគីស្ថាន ដែលមានព្រំដែនជាប់ ជាមួយនឹង ប្រទេសចិន និងប្រទេសអ៊ីរ៉ង់ ដែលប្រទេសទាំងពីរសុទ្ធតែ រង ការវាយប្រហារដ៏ធ្ងន់ធ្ងរ ពីកូរ៉ូណាវីរុសនោះ បានរាយការណ៍ប្រាប់ពី ការរកឃើញករណីឆ្លងកូរ៉ូណា វីរុសដំបូង កាលពីថ្ងៃពុធម្សិលមិញ នេះ៕ ប្រែសម្រួលះប៉ាង កុង

## ៨. ដើមអម្ពិល៖ អាជ្ញាធរនៅកាលីហ្វ័រនីញ៉ា កំពុងធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់ទៅលើ ពលរដ្ឋជាង៨.000នាក់ ដើម្បីស្វែងរកអ្នកផ្ទុកវីរុសកូរ៉ូណា






ព័ត៌មានអន្តរជាតិ

# អាជ្ញាធរនៅកាលីហ្វ័រនីញ៉ា កំពុងធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់ទៅលើ ពលរដ្ឋជាង៨.000នាក់ ដើម្បីស្វែងរកអ្នកផ្ទុកវីរុសកូរ៉ូណា

By YVC111

Posted on February 28, 2020

សាន់ហ្វ្រាន់ស៊ីស្កូ៖ ទូរទស្សន៍សិង្ហបុរី Channel News Asia បានផ្សព្វផ្សាយព័ត៌មានឲ្យ ដឹងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ថា អភិបាលរដ្ឋ Gavin Newsom បានថ្លែងកាលពីថ្ងៃព្រហស្បតិ៍ថា រដ្ឋកាលីហ្វ័រនីញ៉ា កំពុងធ្វើការត្រួតពិនិត្យទៅលើពលរដ្ឋលើសពី៨.៤០០នាក់ ដែលបានមកដល់តាមជើងហោះហើរ ពាណិជ្ជកម្ម ដែលសង្ស័យមានរោគសញ្ញាជំងឺបង្កឡើងដោយកូរ៉ូណាវីរុស ពី "ទិសដៅនៃក្តីបារម្ភ" ប៉ុន្តែ រដ្ឋ នៅមិនទាន់ធ្វើតេស្តទៅលើកុមារតូចៗ និងបានជួយដល់ពួកគេដោយក្រុម ធ្វើតេស្តសហព័ន្ធ ។

---

Adtag for Mobile Underlay:-
កាលីហ្វ័រនីញ៉ា បានធ្វើតេស្តលើកុមារតូចៗតែ២០០នាក់ប៉ុណ្ណោះ ប៉ុន្តែបានធ្វើតេស្តតាមវិធីសារជាច្រើនដើម្បីបង្កើនការត្រួតពិនិត្យ ក្នុងនោះរាប់បញ្ចូលទាំងពលរដ្ឋអាមេរិកាំង ដែលជាអ្នកអាចឆ្លងវីរុស ខណៈដែលវីរុស បានឆ្លងរាលដាលតាមរយៈសហគមន៏ជាច្រើននៅកាលីហ្វ័រនីញ៉ា ។

កាលពីថ្ងៃពុធកន្លងទៅនេះ កាលីហ្វ័រនីញ៉ា បានត្រូវគេរាយការណ៍មកថា មាន០១ករណីនៃអ្នកឆ្លងវីរុសកូរ៉ូណា ដែលមិនទាន់ដឹងប្រភពដើមច្បាស់លាស់នៅឡើយទេ ដែលធ្វើឲ្យរដ្ឋនេះជារដ្ឋដែលមានសក្តានុពលខ្លាំងបំផុតដែលបានឆ្លងវីរុស ដែលរីករាលដាលនៅក្នុងសហគមន៏នានារបស់សហរដ្ឋអាមេរិក ៕ប្រែសម្រួលដោយ៖ ម៉ៅ បុប្ផាមករា

៩. កោះសន្តិភាព៖ កីឡាករ បាល់ទាត់ ម្នាក់ បាន ឆ្លង Covid- 19 ខណៈកំពុងលេង នៅអ៊ីតាលី

កោះសន្តិភាព KOH SANTEPHEAP MEDIA




# កីឡាករបាល់ទាត់ម្នាក់បានឆ្លង Covid-19 ខណៈកំពុងលេងនៅអ៊ីតាលី

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០
ម៉ោង ១៣:៥៩
វីរៈបុត្រ

Share

Like 142

យោងទៅតាមសេចក្តីរាយការណ៍មួយបានឱ្យដឹងថា កីឡាករលេងក្នុងលីគអុីតាលី Serie C ម្នាក់ ត្រូវបានគេធ្វើរោគវិនិច្ឆ័យថា មានផ្ទុកវីរុស Covid-19 ដោយធ្វើឱ្យរូបគេក្លាយជាកីឡាករបាល់ទាត់អាជីពដំបូងគេ ដែលឆ្លងវីរុសនេះ។




យោងតាមកាសែតអុីតាលី La Nazione បានរាយការណ៍ថា កីឡាករបាល់ទាត់វ័យ២២ឆ្នាំម្នាក់ ដែលមិនត្រូវបានបង្ហាញឈ្មោះ ប៉ុន្តែលេងឱ្យក្រុម Pianese ASD ដែលមានមូលដ្ឋានក្នុងតំបន់ Tuscany ភាគខាងលិចប្រទេស ត្រូវបានរកឃើញថាមានផ្ទុកវីរុសថ្មីនេះ។

របាយការណ៍ដដែលបានអះអាងថា កីឡាករបាល់ទាត់រូបនេះបានស្ម័គ្រចិត្ត ដើម្បីទទួលការធ្វើរោគវិនិច្ឆ័យនេះ បន្ទាប់ពីរូបគេមានអាការៈក្តៅខ្លួន និងមានអារម្មណ៍ថាមិនស្រួល មុនពេលចាប់ផ្តើម

ការប្រកួតទល់នឹងក្រុម Juventus U-23 កាលពីថ្ងៃអាទិត្យ មុនពេលក្រុមគ្រូពេទ្យសំរេចចិត្តធ្វើតេស្ត ហើយបញ្ជាក់ថា មានសញ្ញាវិជ្ជមាន។ ដកស្រង់ចេញពីគេហទំព័រ Metro។

១០. កោះសន្តិភាព៖ ប្រណាំង កង់ UAE Tour ត្រូវ លុប ចោល  ពាក់កណ្តាល ទី  ដោយ Covid-19




# ប្រណាំងកង់ UAE Tour ត្រូវលុបចោលពាក់កណ្តាលទី ដោយCovid-19

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០
ម៉ោង ១៣:៤៩
វីរៈបុត្រ


Share
Like 93

ការប្រកួតប្រណាំងកង់ UAE Tour ត្រូវលុបចោលពាក់កណ្ដាលទីដោយសារ Covid-19 ការប្រកួតប្រណាំងកង់ UAE Tour ត្រូវបានលុបចោល ដោយនៅសល់២ដំណាក់កាលទៀត បន្ទាប់ពីបុគ្គលិកជាជនជាតិអ៊ីតាលីពីរនាក់ បានធ្វើតេស្តរកឃើញថាមានផ្ទុកវីរុស Covid-19 នេះបើតាមការចុះផ្សាយពី BBC។




អ្នកជិះក្នុងព្រឹត្តិការណ៍នោះ រួមមានទាំងកីឡាកររបស់អង់គ្លេស Chris Froome និង Adam Yates ពេលនេះក៏កំពុងត្រូវបានធ្វើតេស្តរកវីរុសនេះផងដែរ។ ក្រុមអ្នករៀបចំការប្រកួតកីឡា របស់ទីក្រុងអាប៊ូដាប៊ីនៃសហព័ន្ធអារ៉ាប់រួម បាននិយាយថា «សុវត្ថិភាពបានក្លាយជាអាទិភាពកំពូលទាំងអស់នៅពេលនេះ»។ ការសម្រេចចិត្តត្រូវបានធ្វើឡើង ដើម្បីធានាការការពារដល់អ្នកចូលរួមទាំងអស់។

ហើយក្នុងការប្រណាំងដំណាក់កាលបន្ទាប់ត្រូវបានលុបចោល ដោយបានជូនដំណឹងដល់ក្រុមការងារ និងអ្នកប្រណាំងទាំងអស់ កាលពីល្ងាចថ្ងៃព្រហស្បតិ៍។ នៅមិនទាន់មានការបញ្ជាក់ណាមួយ បន្ថែមទៀត ក្រោយការលុបចោលនេះនៅឡើយទេ។




គួរឱ្យដឹងថា មនុស្សប្រមាណជាង ៨០.០០០នាក់នៅក្នុងប្រទេស ជិត ៥០ត្រូវបានរាយការណ៍ថា បានឆ្លងវីរុសនេះ ខណៈជិត ២៨០០នាក់បានស្លាប់ ដែលភាគច្រើននៃការស្លាប់នៅក្នុងប្រទេស ចិន។




# វីរុស COVID-19 កាន់តែខ្លាំងនាំឲ្យពិភពលោកទាំងមូលមានការព្រួយបារម្ភ

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០
ម៉ោង ០៧:១០
ខាន់ សុខឃន

Share

Like 1K

ប្រទេសអ៊ីតាលី ៖ វីរុស COVID-19 ពេលនេះបានឆ្លងរាលដាលកាន់តែខ្លាំង រហូតដល់អាមេរិកឡាទីន ដោយចូលដល់ប្រទេសប្រេស៊ីល ហើយបន្តឆ្លងរាលដាលនៅអឺរ៉ុប និងអាស៊ី ដែលនាំឲ្យពិភពលោកទាំងមូលមានការព្រួយបារម្ភកាន់តែខ្លាំង។




នៅប្រេស៊ីលបុរសចំណាស់ម្នាក់រស់នៅក្រុងសាវប៉ូឡូបានឆ្លងវីរុសនេះ ក្រោយត្រឡប់មកពីអ៊ីតាលីជាប្រទេសអឺរ៉ុបមួយដែលរងការប៉ះពាល់ខ្លាំង។ ប្រទេសប៉ាគីស្ថានមានព្រំដែនជាប់ចិន និងអ៊ីរ៉ង់ដែលមានមនុស្សបាត់បង់ជីវិតកាន់តែច្រើនដោយសារវីរុស បានប្រកាសនាថ្ងៃទី២៦ កុម្ភៈ ពីអ្នកឆ្លងដំបូង២នាក់។ នៅអឺរ៉ុបប្រទេសស្វីស អូទ្រីស ក្រូអាស៊ី ម៉ាសេដូនីនិងក្រិក ពេលនេះក៏រងការប៉ះពាល់ដោយវីរុសCOVID-19 ហើយបារាំងប្រកាសនាថ្ងៃទី២៦កុម្ភៈពីជនជាតិខ្លួនដំបូងជាសាស្ត្រាចារ្យវិទ្យាល័យម្នាក់បាត់បង់ជីវិតដោយរូបគេពុំធ្លាប់ទាំងធ្វើដំណើរចូលក្នុងតំបន់មានគ្រោះថ្នាក់។

នោះជាអ្នកបាត់បង់ជីវិតទី២នៅបារាំងបន្ទាប់ពីស្ត្រីអ្នកទេសចរចិនម្នាក់។

វីរុសCOVID-19ពេលនេះទាក់ទិនក្រៅពីចិន ដល់ប្រទេសនិងតំបន់ប្រមាណជា៤០។ ប៉ុន្តែការឆ្លងហាក់ដូចជាដល់ចំណុចកំពូលនៅចិន ហើយធ្លាក់ចុះវិញបណ្តើរៗ។ អាជ្ញាធរសុខាភិបាលចិនប្រកាសនាថ្ងៃទី២៦កុម្ភៈពីអ្នកបាត់បង់ជីវិតថ្មីតែ៥២នាក់ រយៈពេល២៤ម៉ោងក្នុងប្រទេស ជាតួលេខដ៏ទាបបំផុតចាប់តាំងពីជាង៣សប្តាហ៍មកនេះ។




អ៊ីតាលីជាមួយអ្នកឆ្លងវីរុសនេះជាង៣៧០នាក់និងអ្នកបាត់បង់ជីវិត១២នាក់ ពេលនេះក្លាយជាប្រភពនៃការចម្លងសំខាន់នៅអឺរ៉ុប ជាហេតុនាំឲ្យប្រទេសជាច្រើនក្នុងទ្វីបនេះ ពង្រឹងបណ្តាវិធានការបង្ការនិងរិតត្បិត។ ប្រទេសជាច្រើនបានណែនាំពលរដ្ឋពួកគេ កុំឲ្យ

ទៅកាន់បណ្ដាតំបន់រងការប៉ះពាល់ដោយវីរុសនៅអ៊ីតាលី ពិសេស អេស្ប៉ាញ អង់គ្លេស អូទ្រីស ហុងគ្រី អ៊ុយក្រែន លុចហ្សំបួរ ឆេកនិង រូម៉ានី។

*អ៊ីរ៉ង់មានអ្នកបាត់បង់ជីវិតដល់១៩នាក់*

តុល្យការចុងក្រោយទាក់ទិននឹងការឆ្លងរាលដាលនៃវីរុសCOVID-19 នៅអ៊ីរ៉ង់មានអ្នកឆ្លងដល់១៣៩នាក់ ហើយអ្នកបាត់បង់ជីវិតមានដល់១៩នាក់។ នេះជាការអះអាងនាថ្ងៃទី២៦កុម្ភៈរបស់អ្នកនាំំពាក្យក្រសួងសុខាភិបាលអ៊ីរ៉ង់ ក្នុងសង្កថាតាមទូរទស្សន៍រដ្ឋ។ ក្រៅពីចិនដីគោក អ៊ីរ៉ង់ជាប្រទេសដែលមានចំនួនអ្នកបាត់បង់ជីវិតដោយសារវីរុសនោះច្រើន និងក្នុងអត្រាដ៏ខ្ពស់៕ ដកស្រង់ចេញពីវេបសាយ ៖ yahoo (កែសម្រួលដោយ ៖ បុប្ផា)

## ១២. កម្ពុជាថ្មី៖ ៥ប្រទេសថ្មីរាយការណ៍ពីករណីឆ្លងវីរុស Covid-19 លើកដំបូង ក្នុង រយៈពេល ១៥ ម៉ោង ចុងក្រោយ

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY












# ៥ប្រទេសថ្មីរាយការណ៍ពីករណីឆ្លងវីរុស covid-19 លើកដំបូង ក្នុងរយៈពេល ១៥ម៉ោងចុងក្រោយ

28/2/2020 3:39 Pm KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព

♡ 1

បណ្ដាប្រទេសជាច្រើននៅទូទាំងពិភពលោកបានរាយការណ៍ពីករណីលើកដំបូងរបស់ខ្លួនក្នុងរយៈពេល ១៥ ម៉ោងចុងក្រោយនេះ។ ប្រទេសទាំងនោះរួមមាន ហូឡង់ នីហ្សេរីយ៉ា លីទុយអានី បេឡារុស្ស និង នូវែលសេឡង់។

បន្ទាប់ពីប្រទេសប្រេស៊ីលបានបញ្ជាក់ពីករណីមួយកាលពីថ្ងៃអង្គារ ពេលនេះការឆ្លងរាលដាលដ៏លឿននៃវីរុស Covid-19 បានទៅដល់គ្រប់ទ្វីបទាំងអស់ លើកលែងតែទ្វីបអង់តាក់ទិកប៉ុណ្ណោះ។

គិតត្រឹមរសៀលថ្ងៃសុក្រនេះមានករណីឆ្លងវីរុស Covid-19 ជាង ៤៤០០ ករណីត្រូវបានបញ្ជាក់នៅខាងក្រៅប្រទេសចិន និងមានមនុស្សស្លាប់យ៉ាងហោចណាស់ចំនួន ៦៧ នាក់។ ក្នុងនោះប្រទេសកូរ៉េខាងត្បូងបានបញ្ជាក់ពីករណីឆ្លងវីរុសនេះច្រើនបំផុតបន្ទាប់ពីប្រទេសចិនដែលមានចំនួនសរុប ២ ៣៣៧ ករណី។ នៅក្នុងប្រទេសអ៊ីតាលីវិញការផ្ទុះឡើងនៃវីរុសបានបន្តកាន់តែអាក្រក់ទៅៗ ដោយមានរបាយការណ៍បញ្ជាក់ថាមានអ្នកឆ្លងយ៉ាងហោចណាស់ ៦៥០ ករណី។

លើសពីនេះទៀតមាន ២៧០ ករណីត្រូវបានបញ្ជាក់នៅក្នុងប្រទេសអ៊ីរ៉ង់ និងមានអ្នកស្លាប់ដល់ទៅ ២៦ នាក់ក្នុងប្រទេសនេះ។ សូម្បីតែអនុប្រធានាធិបតីនិងអនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលក៏បានឆ្លងជំងឺកូរ៉ូណា ខណៈដែលអតីតឯកអគ្គរដ្ឋទូតរបស់ខ្លួនលោក Vatican Hadi

Khosroshah កាលពីថ្ងៃព្រហស្បតិ៍បានទទួលមរណភាពដោយសារការឆ្លងវីរុសនេះដែរ។

ទន្ទឹមនឹងនេះដែរប្រទេសចិនបានរាយការណ៍នៅថ្ងៃព្រហស្បតិ៍ម្សិលមិញថា ចំពេលដែលមានការរីករាលដាលជាសកលនៃវីរុស Covid-19 មានតែ ៩ ករណីថ្មីប៉ុណ្ណោះនៅខាងក្រៅខេត្តហ៊ូប៉ី៕

ចុចអាន៖ ក្រុមហ៊ុនធំៗក្នុងប្រទេសកូរ៉េខាងត្បូងផ្តល់ជំនួយរាប់លានដុល្លារដើម្បីប្រឆាំងនឹងវីរុស Covid-19

ចុចអាន៖ មន្ទីរពេទ្យចិនបញ្ជាក់ថាបានព្យាបាលអ្នកជំងឺ COVID-19 ជាសះស្បើយជាង ៣មុឺននាក់ហើយ

ប្រែសម្រួល៖ សន្យា

## ១៣. កម្ពុជាថ្មី៖ អ្នក ជំនាញ សុខាភិបាល អះអាង ថា មេរោគ កូរ៉ូ ណា វីរុស ប្រភេទ ថ្មី ឆ្លង តាមរយៈ ដំណក់ ទឹក តូចៗ របស់ អ្នក ជំងឺ



# អ្នកជំនាញសុខាភិបាលអះអាងថា មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗរបស់អ្នកជំងឺ

28/2/2020 4:24 Pm ជាតិទូទៅ, ព័ត៌មានជាតិ, សុខភាព

like

ភ្នំពេញ ៖ អ្នកជំនាញសុខាភិបាលបានអះអាងថា មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឬជំងឺកូវីដ១៩ ឆ្លងតាមរយៈដំណក់ទឹកតូចៗអ្នកជំងឺដែលខ្ចាតចេញមកក្រៅតាមរយៈក្អក ឬកណ្តាស់នៅពេលដែលអ្នកនៅជិតដិតជាមួយអ្នកជំងឺ ឬបានប៉ះពាល់ទៅលើវត្ថុដែលទាំងឡាយរបស់អ្នកជំងឺ។

ការបង្ហាញពីវិធីឆ្លង នៃមេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឬកូវីដ១៩ គឺដើម្បីឲ្យសាធារណជន បានយល់ដឹងកាន់តែច្បាស់ថែមទៀត ដើម្បីបញ្ចៀសកុំឆ្លងជំងឺនេះនៅក្នុងប្រទេសកម្ពុជា។

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានលើកឡើងនៅក្នុងផេកផ្លូវការរបស់ខ្លួនថា មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗដែលខ្ចាតចេញមកក្រៅតាមរយៈក្អក ឬកណ្តាស់ ហើយត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះដែរ។

លោកវេជ្ជបណ្ឌិត បានលើកឡើងពីអ្នកវិទ្យាសាស្ត្ររកឃើញថា ចម្ងាយខ្ចាតចេញពីមុខមនុស្សយើងចម្ងាយបាន៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រ គឺ៩០សង់ទីម៉ែត្រ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ។

លោកវេជ្ជបណ្ឌិតបានបន្តទៀតថា ពេលអ្នកជំងឺក្អក ឬកណ្តាស់ម្តងៗ បណ្តាលឲ្យខ្ទាតដំណក់តូចៗទាំងនោះទៅលើផ្ទៃផ្សេងៗ ដូចជា លើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ល។ និងដៃរបស់គាត់ក្រោយញើច្រមុះ ប្រឡាក់សំបោរ ប៉ះដៃទ្វារ ប៉ះជញ្ជាំង ប៉ះបង្កាន់ដៃ ហើយពេលយើងប៉ះលើវត្ថុទាំងនោះ នឹងបណ្តាលឲ្យឆ្លងពេលយើងយកដៃទៅប៉ះមុខ និងច្រមុះ។

ជាមួយគ្នានេះដែរ អ្នកវិទ្យាសាស្រ្ត ក៏បានរកឃើញទៀតថា ក្នុងមួយថ្ងៃ មនុស្សយើងប៉ះមុខជាមធ្យម ៦០ដង។ ហេតុដូច្នេះ តម្រូវឲ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឲ្យខ្ទាតចេញមកក្រៅ និងទាំងអ្នកឈឺ និងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ជេល ជាដើម។

ចំពោះព័ត៌មានបន្ថែម សាធារណជនអាចធ្វើការទាក់ទងមកលេខ១១៥ ដោយឥតគិតថ្លៃពីគ្រប់ប្រព័ន្ធ។ ទូរសព្ទទាន់ហេតុការណ៍១១៥ ជាប្រព័ន្ធទូរសព្ទបានអភិវឌ្ឍន៍ទៅជាបច្ចេកវិទ្យាទំនើប និងសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋទូទាំងប្រទេសនូវ ៖
១.ចំណេះដឹងទាក់ទងនឹងជំងឺកូរ៉ូណាវីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត។
២.អាចរាយការណ៍ករណីជំងឺសង្ស័យ និងកើតឡើងច្រើនខុសធម្មតាក្នុងទីតាំងណាមួយ។
៣.អាចសួរព័ត៌មាន ឬចំណេះដឹងបន្ថែមទាក់ទងនឹងជំងឺកូរ៉ូណាវីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត។
៤.យើងមានសហការីជំនាញសុខាភិបាល១០រូបចាំទទួលទូរសព្ទ ដោយប្រើបច្ចេកវិទ្យា ប្រព័ន្ធបញ្ជូនទៅទូរស័ព្ទដៃទៅគ្រូពេទ្យទាំង១០នាក់ (Calling Forward System)។

គួររំលឹកថា រហូតមកដល់ពេលនេះ កម្ពុជា នៅមិនទាន់មានករណីឆ្លង ជំងឺកូវីដ១៩ថ្មីនេះបន្ថែមទៀតទេ ពោលគឺមានតែមួយករណីទៅលើ ជនជាតិចិនម្នាក់ អាយុ៦០ឆ្នាំ នៅខេត្តព្រះសីហនុ ហើយបានព្យាបាល ជាសះស្បើយ និងបានវិលត្រឡប់ទៅប្រទេសចិនវិញ ខណៈមានអ្នក ឆ្លងជំងឺ COVID-19 ជាង ៨១ ០០០ នាក់ និងមានអ្នកស្លាប់ជាង ២ ៧៦០ នាក់ នៅតាមបណ្តាប្រទេស៥១ ក្នុងនោះ រួមមាន ចិន (បញ្ចូលទាំងតំបន់ រដ្ឋបាលពិសេសហុងកុង តៃវ៉ាន់ និងម៉ាកាវ) កូរ៉េខាងត្បូង ជប៉ុន (បូក ករណីនាវា Diamond Princess) អ៊ីរ៉ង់ សិង្ហបុរី ថៃ អេមីរ៉ាតអារ៉ាប់រួម ម៉ាឡេស៊ី វៀតណាម អូម៉ង់ ហ្វីលីពីន លីបង់ អ៊ីរ៉ាក់ កូវ៉ែត ប៉ារ៉ែន អាហ្វ ហ្គានីស្ថាន ឥណ្ឌា នេប៉ាល់ កម្ពុជា ស្រីលង្កា ប៉ាគីស្ថាន។

ចំណែកនៅបណ្តាប្រទេសនៅអឺរ៉ុប មាន អ៊ីតាលី បារាំង ចក្រភព អង់គ្លេស (មានករណីនៅអង់គ្លេស និងអៀរឡង់ខាងជើង) អាល្លឺម៉ង់ ស៊ុយអែត រុស្ស៊ី អ៊ីស្រាអែល អេស្ប៉ាញ ហ្វាំងឡង់ បែលហ្ស៊ិក អូទ្រីស ក្រូអាស៊ី ស្វីស ក្រិក រូម៉ានី នំរវេស ម៉ាសេដ្វានខាងជើង ហ្សកហ្ស៊ី ដា ណឺម៉ាក អេស្តូនី ហុល្លង់ និងសាំងម៉ារាំង និងលីទុយអានី។ ក្រៅពីនោះ មាននៅសហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី អេហ្ស៊ីប អាល់ហ្សេរី នីហ្សេរីយ៉ា និងប្រេស៊ីល៕

## ១៤. កម្ពុជាថ្មី៖ ក្រុមហ៊ុនធំៗក្នុងប្រទេសកូរ៉េខាងត្បូងផ្តល់ជំនួយរាប់លានដុល្លារដើម្បីប្រឆាំងនឹងវីរុស Covid-19

កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY







Home > KPT Plus > ក្រុមហ៊ុនធំៗក្នុងប្រទេសកូរ៉េខាងត្បូងផ្តល់ជំនួយរាប់លានដុល្លារដើម្បីប្រឆាំងនឹងវីរុស Covid-19

# ក្រុមហ៊ុនធំៗក្នុងប្រទេសកូរ៉េខាងត្បូងផ្តល់ជំនួយរាប់លានដុល្លារដើម្បីប្រឆាំងនឹងវីរុស covid-19

28/2/2020 3:07 Pm KPT Plus, ព័ត៌មានអន្តរជាតិ, សុខភាព

like

ក្រុមហ៊ុនធំៗនៅក្នុងប្រទេសកូរ៉េខាងត្បូងរួមមានក្រុមហ៊ុន Samsung ក្រុមហ៊ុន Hyundai ក្រុមហ៊ុន SK ក្រុមហ៊ុន LG និងក្រុមហ៊ុនផ្សេងទៀតកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីគាំទ្រដល់ប្រទេសកូរ៉េខាងត្បូងដែលកំពុងរងគ្រោះដោយវីរុស Covid-19 ដោយផ្តល់នូវការបរិច្ចាគថវិកានិងការផ្គត់ផ្គង់សម្ភារវេជ្ជសាស្រ្តដល់ដល់ប្រទេសនេះ។

ការផ្តល់ជំនួយសង្គ្រោះភាគច្រើនផ្តោតលើទីក្រុងភាគអាគ្នេយ៍នៃទីក្រុង Daegu និងខេត្ត Gyeongsang ដែលជាតំបន់រងផលប៉ះពាល់ខ្លាំងបំផុតពីវីរុស។

ក្រុមហ៊ុន Samsung Group ដែលជាក្រុមហ៊ុនបច្ចេកវិទ្យាធំជាងគេរបស់ប្រទេសបានបរិច្ចាគប្រាក់ចំនួន ៣០ ពាន់លានវ៉ុន ឬ ២៤,៦ លានដុល្លារ ដើម្បីជួយក្នុងការផ្គត់ផ្គង់គ្រឿងវេជ្ជសាស្រ្តនិងសេវាកម្មផ្សេងៗទៀត។

ក្រុមហ៊ុន Hyundai Group ក៏បានបរិច្ចាគទឹកប្រាក់ចំនួន ៥ ពាន់លានវ៉ុន ឬជាង ៤លានដុល្លារ ដល់សហគមន៍ដើម្បីជួយសង្គ្រោះគ្រោះមហន្តរាយកូរ៉េផងដែរ។ អំណោយនេះនឹងត្រូវប្រើសម្រាប់ទិញឧបករណ៍ប្រឆាំងនឹងការឆ្លង និងគាំទ្រសកម្មភាពបង្ការការរីករាលដាលនៃវីរុស ដោយផ្តល់ជូនដល់ក្រុមគ្រួសារដែលមានចំណូលទាប បុ ពេទ្យ និងអ្នកគ្មានទីពឹង។

លោក Chung Euisun អនុប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុន Hyundai មានប្រសាសន៍ថា អំណោយរបស់ក្រុមហ៊ុននឹងជួយដោយផ្ទាល់ដល់បុគ្គលិកពេទ្យដែលខិតខំធ្វើការព្យាបាលនិងអ្នកដែលកំពុងធ្វើសកម្មភាពសម្អាត។

ក្រុមហ៊ុន SK Group ក៏បានប្រកាសផងដែរនូវទឹកប្រាក់ចំនួន ៥ ពាន់លានវ៉ុនក្នុងការបរិច្ចាគទៅសហគមន៍នៃប្រទេសកូរ៉េដើម្បីជួយដល់អ្នកដែលរងគ្រោះដោយសារវីរុស។ ក្រុមហ៊ុននេះនឹងចំណាយថវិកាចំនួន ៤០០ លានវ៉ុនបន្ថែមទៀត ដើម្បីផ្តល់ជូននូវម៉ាស់និងទឹកអនាម័យដៃផងដែរដល់ក្រុង Daegu និងខេត្ត North Gyeongsang ។

ស្រដៀងគ្នានេះដែរក្រុមហ៊ុន LG Group បានបរិច្ចាគទឹកប្រាក់ចំនួន ៥ ពាន់លានវ៉ុនដល់សហគមន៍កូរ៉េដើម្បីជួយដល់ប្រជាជនដែលរស់នៅក្នុងទីក្រុង Daegu និងខេត្ត North Gyeongsang ។ ក្រៅពីការបរិច្ចាគនេះក្រុមហ៊ុន LG Household & Healthcare ក៏នឹងចំណាយប្រាក់ ១ ពាន់លានវ៉ុនដើម្បីជូនទឹកអនាម័យដៃដល់ប្រជាជននៅតំបន់នោះផងដែរ។

ក្រៅពីក្រុមហ៊ុនធំៗខាងលើមានក្រុមហ៊ុនផ្សេងទៀតដូចជា ក្រុមហ៊ុន POSCO ជាក្រុមហ៊ុនផលិតដែកថែបធំជាងគេរបស់ប្រទេសបានប្រកាសផ្តល់ជំនួយចំនួន ៥ ពាន់លានវ៉ុនដែរ។ លើសពីនេះទៀតមានក្រុមហ៊ុន Lotte ក្រុមហ៊ុន GS Group ក្រុមហ៊ុន Doosan Group និងក្រុមហ៊ុន CJ Group បានផ្តល់ប្រាក់ជំនួយ ១ ពាន់លានវ៉ុនក្នុងមួយក្រុមហ៊ុន។

បន្ថែមពីលើក្រុមហ៊ុនក្នុងស្រុកខាងលើ ម្ចាស់មេដាយមាសកីឡាអូឡាំពិកកញ្ញា Kim Yuna និងអ្នកគាំទ្ររបស់នាងបានបរិច្ចាគប្រាក់សរុបចំនួន ១០៨.៥ លានវ៉ុនឬជិត ៩០ម៉ឺនដុល្លារ ទៅអង្គការ UNICEF កូរ៉េដើម្បីជួយដល់ប្រទេសកូរ៉េខាងត្បូងដែរ។

គិតមកត្រឹមថ្ងៃសុក្រនេះប្រទេសកូរ៉េខាងត្បូងមានអ្នកឆ្លងសរុបជាង ២ ០០០ នាក់ និងមានអ្នកស្លាប់ ១៣ នាក់។ ភាគច្រើននៃករណីដែលបានបញ្ជាក់គឺនៅក្នុងក្រុង Daegu និងខេត្ត Gyeongsang ភាគខាងជើងនៃប្រទេស៕

ចុចអាន៖ > ប្រទេស ៥២ លើពិភពលោកកំពុងរឹតត្បិតចំពោះអ្នកដំណើរមកពីកូរ៉េខាងត្បូង

ចុចអាន៖ ប◌្រទេសអ៊ីរ៉ង់ទទួលបានឧបករណ៍ធ្វើតេស្តមេរោគកូរ៉ូណា ចំនួន ២ ម៉ឺនគ្រឿងពីប្រទេសចិន

**ប្រែសម្រួល៖ សន្យា**